## ២- សេចក្ដីសំរេច

រាជធានីភ្នំពេញ,ថ្ងៃទី០១ ខែកក្កដា ឆ្នាំ១៩៩៩

### សេចក្ដីសំរេចលេខ ២០ សសរ
### ស្ដីពីការផ្ទេរសិទ្ធិ

***

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្ដម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៥៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩៧ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-យោងតាមសំណូមពរការងារចាំបាច់

**សំរេច**

ប្រការ ១ : ផ្ទេរសិទ្ធិជូនឯកឧត្ដម **ស៊ុយ សែម** រដ្ឋលេខាធិការនៃ ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន អោយទទួលបន្ទុកបន្ថែម ជារដ្ឋមន្ត្រីស្ដីទី នៃក្រសួងផែនការ ជំនួស ឯកឧត្ដម **ឆាយ ថន** ដែលត្រូវបានអនុញ្ញាតច្បាប់ឈប់ពិសេស ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន និង ឯកឧត្ដម **ស៊ុយ សែម** ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសំរេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

**អ៊ឹុង ហួត** **ហ៊ុន សែន**

★ ★ ★

រាជធានីភ្នំពេញ,ថ្ងៃទី០១ ខែកក្កដា ឆ្នាំ១៩៩៩

### សេចក្ដីសំរេចលេខ ២១ សសរ
### ស្ដីពីការផ្ទេរសិទ្ធិ

***

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា